# ការប្រាស្រ័យទាក់ទងល្អគួរតែមាន៖

១ ការបង្កើតការជឿទុកចិត្ត បង្ហាញចំណាប់អារម្មណ៍ និងការយល់ចិត្ត

២ ផ្តល់ការទទួលស្គាល់ និងការកោតសរសើរ

៣ ការសួរសំណួរ និងការប្រាស្រ័យទាក់ទងទៅវិញទៅមក

៤ ការប្រើប្រាស់កាយវិការឲ្យបានសមស្រប

៥ ស្តាប់ដោយយកចិត្តទុកដាក់ និងសកម្ម

៦ ការសួរទៅបុគ្គលនោះជាមុន ថាតើគាត់ចង់ឲ្យអ្នកហៅគាត់បែបណា

## របៀបប្រាស្រ័យទាក់ទងជាមួយ ជនមានការពិបាកក្នុងការនិយាយ៖

១ ទុកពេលឲ្យគាត់និយាយឲ្យបានគ្រប់គ្រាន់

២ សូមកុំរំខាន បង្អាក់ ឬនិយាយបំពេញប្រយោគជំនួសគាត់

៣ សូមកុំធ្វើពុតថាអ្នកបានយល់ ប្រសិនបើអ្នកមិនយល់ពីអ្វីដែលគាត់និយាយ

៤ វាមិនអីទេក្នុងការស្នើសុំឲ្យគាត់និយាយម្តងទៀត ហើយបញ្ជាក់ឲ្យបានច្បាស់

៥ ឲ្យនរណាម្នាក់ចូលរួម ដើម្បីជួយក្នុងការទំនាក់ទំនងនោះ ប្រសិនបើចាំបាច់

## របៀបប្រាស្រ័យទាក់ទងជាមួយ ជនមានការពិបាកក្នុងការមើល៖

១ បញ្ជាក់ពីខ្លួនអ្នកឲ្យបានច្បាស់ ពេលចាប់ផ្តើមនិយាយទៅកាន់គាត់

២ ត្រូវប្រាកដថាមនុស្សគ្រប់គ្នាបានណែនាំខ្លួនរបស់ពួកគេដោយការនិយាយ

៣ ជូនដំណឹងទៅគាត់នៅពេលមានមនុស្សចូល ឬចាកចេញពីបន្ទប់

៤ សូមនិយាយជាមួយគាត់ដោយផ្ទាល់

៥ សូមហៅឈ្មោះរបស់គាត់ នៅពេលដែលអ្នកនិយាយសំដៅទៅលើគាត់

៦ និយាយធម្មតា ច្បាស់ៗ និងមិនចាំបាច់ស្រែក ឬនិយាយឮៗនោះទេ

៧ សួរប្រសិនបើគាត់ត្រូវការជំនួយ។ សូមកុំប៉ះពាល់ ឬធ្វើអ្វីមួយដែលគាត់មិនបានស្នើសុំ។



## របៀបប្រាស្រ័យទាក់ទងជាមួយ ជនមានការពិបាកក្នុងការផ្លាស់ទី៖

១ ព្យាយាមបន្ទាបខ្លួនរបស់អ្នកឲ្យស្មើគ្នានឹងកម្រិតនៃភ្នែករបស់គាត់ នៅពេលនិយាយជាមួយគាត់

២ និយាយទៅកាន់គាត់ផ្ទាល់ មិនមែននិយាយជាមួយជំនួយការ ឬអ្នកមើលថែគាត់នោះទេ

៣ មិនត្រូវយកឧបករណ៍ជំនួយចេញពីកន្លែងដែលគាត់បានទុកវានោះទេ

៤ សួរគាត់ថា តើគាត់ត្រូវការជំនួយដែរឬទេ មុននឹងជួយគាត់

៥ ត្រូវប្រាកដថាផ្លូវធំទូលាយ និងមិនមានវត្ថុរាំងដល់ការចល័តទីរបស់គាត់

៦ ត្រូវទុកចន្លោះទំនេរនៅតុនីមួយៗ ដើម្បីងាយស្រួលសម្រាប់អ្នកប្រើរទេះចូលរួម

## របៀបប្រាស្រ័យទាក់ទងជាមួយ ជនមានការពិបាកក្នុងការស្តាប់៖

១ ឈរនៅកន្លែងណាដែលគាត់អាចមើលឃើញអ្នកច្បាស់

២ និយាយទល់មុខគ្នា ដូចនេះគាត់អាចមើលឃើញពីទឹកមុខ និងការបង្ហាញរបស់អ្នក

៣ ត្រូវដឹងអំពីការធ្វើចលនានៃបបូរមាត់ ដើម្បីឲ្យអ្នកកំពុងមើលបានយល់

៤ សួរពីរបៀបដែលគាត់ចូលចិត្តក្នុងការទំនាក់ទំនង

៥ ពិនិត្យមើលថាតើគាត់បានយល់ពីអ្វីដែលអ្នកបាននិយាយដែរឬទេ

៦ និយាយពីសារសំខាន់ៗឡើងវិញម្តងទៀត ឧទាហរណ៍ការសរសេរលើក្រដាស

៧ និយាយមួយៗ ច្បាស់ៗ ហើយសូមកុំស្រែក

៨ និយាយទៅកាន់គាត់ផ្ទាល់ កុំនិយាយជាមួយគាត់តាមរយៈអ្នកដទៃ

៩ ប្រើទឹកមុខ និងកាយវិការ ដើម្បីគាំទ្រ ឬបង្ហាញបន្ថែមលើអ្វីដែលអ្នកកំពុងនិយាយ

## របៀបប្រាស្រ័យទាក់ទងជាមួយ ជនមានការពិបាកក្នុងការរៀនសូត្រ៖

១ និយាយឲ្យច្បាស់ ប្រើប្រយោគខ្លីៗ និងប្រើពាក្យដែលងាយស្រួលយល់

២ និយាយមួយៗ និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់គាត់ក្នុងការឆ្លើយតប

៣ ប្រើរូបភាព ឬវត្ថុផ្សេងៗដើម្បីជាជំនួយនៃការពន្យល់របស់អ្នក

៤ ប្រើប្រាស់កាយវិការ ឬទឹកមុខ ដើម្បីបង្ហាញពីសភាពអ្វីមួយ

៥ ពិនិត្យមើលថាតើគាត់យល់ពីអ្វីដែលអ្នកបាននិយាយ

៦ ឲ្យនរណាម្នាក់ចូលរួម ដើម្បីជួយក្នុងការទំនាក់ទំនងនោះ ប្រសិនបើចាំបាច់

ផលិតដោយ៖ LIGHT FOR THE WORLD, UNDP

គាំទ្រដោយ៖ Australian Aid, ACCESS Sustainable quality services for all